អង្គភាពសវនកម្មផ្ទៃក្នុង
INTERNAL AUDIT UNIT

# អត្ថបទប្រចាំខែ

លេខ ១ ចេញផ្សាយ ខែមករា ឆ្នាំ២០២២

## សវនកម្មជាអ្វី?




កាលពី៤០០ឆ្នាំមុនគ.ស ដំណើរការសវនកម្មត្រូវបានអង្កេតឃើញដំបូងដែលកាលនោះជនជាតិ អេហ្ស៊ីប (Egyptian) និងបាប៊ីឡូន (Babylonian) បានត្រួតពិនិត្យលើសកម្មភាពចេញ-ចូលទំនិញក្នុងឃ្លាំង ហើយរបាយការណ៍ត្រូវបានរាយការណ៍ដោយផ្ទាល់មាត់ដូច្នេះហើយទើបពាក្យសវនកម្មជាភាសាឡាតាំងមានន័យថា“ **ការស្តាប់**”។ ដំណើរការសវនកម្មត្រូវបានវិវត្តន៍ទៅតាមសម័យកាលផ្សេងៗគ្នា បើតាមការស្រាវជ្រាវសវនកម្មនាសម័យបុរាណត្រូវបានរកឃើញនៅប្រទេសចិន(China) អេហ្ស៊ីប(Egypt) និងក្រិក (Greece) ដែលក្នុងចំណោមទម្រង់សវនកម្មទាំងនោះ មានតែប្រទេសក្រិកទេដែលមានសកម្មភាពត្រួតពិនិត្យប្រហាក់ប្រហែលនឹងសវនកម្មនាពេលបច្ចុប្បន្ន។ ជាការអនុវត្តនៅព្រះរាជាណាចក្រកម្ពុជា ដំណើរការសវនកម្មត្រូវបានកំណត់ស្របតាមច្បាប់ស្តីពី**សវនកម្មនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានអនុម័តដាក់ឱ្យប្រើប្រាស់ក្នុងឆ្នាំ២០០០, ច្បាប់ស្តីពី **គណនេយ្យ និងសវនកម្ម** ត្រូវបានអនុម័តដាក់ឱ្យប្រើប្រាស់ក្នុងឆ្នាំ២០១៦ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

**សវនកម្ម** សំដៅដល់ការត្រួតពិនិត្យ និងវាយតម្លៃដោយឯករាជ្យ និងជាប្រព័ន្ធលើទិន្នន័យ របាយការណ៍ កំណត់ត្រា កិច្ចប្រតិបត្តិការ និងលទ្ធផលជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុរបស់សហគ្រាស សម្រាប់គោលបំណងជាក់លាក់ណាមួយ។

**សវនកម្មត្រូវបានបែងចែកជា ២ ប្រភេទគឺ សវនកម្មផ្ទៃក្នុង និង សវនកម្មផ្ទៃក្រៅ។**

**សវនកម្មផ្ទៃក្នុង** សំដៅដល់ការវាយតម្លៃដោយឯករាជ្យលើប្រព័ន្ធគ្រប់គ្រងការដឹកនាំរបស់អង្គភាពដោយមន្ត្រីរបស់ខ្លួនដើម្បីឱ្យប្រតិបត្តិការរបស់អង្គភាពមានប្រសិទ្ធភាព សន្សំសំចៃ និងប្រសិទ្ធផលព្រមទាំងទប់ស្កាត់ការខ្ជះខ្ជាយ និងកំហុសអចេតនានៅក្នុងការប្រើប្រាស់ថវិកា និងទ្រព្យសម្បត្តិ។ សវនកម្មផ្ទៃក្នុងក៏ផ្តល់ផងដែរនូវសេវាប្រឹក្សាសំដៅបន្ថែមតម្លៃ និងកែលម្អប្រតិបត្តិការរបស់អង្គភាព និងជួយអង្គភាពឱ្យសម្រេចគោលបំណងដោយប្រើប្រាស់នូវអភិក្រមជាប្រព័ន្ធនិងដោយជំនាញ ក្នុងការវាយតម្លៃ និងធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធផលនៃការគ្រប់គ្រងហានិភ័យ ដំណើរការត្រួតពិនិត្យ និងអភិបាលកិច្ច។

**សវនកម្មផ្ទៃក្រៅ** សំដៅដល់ការពិនិត្យពិចារណា ឬការពិនិត្យឡើងវិញលើកិច្ចបញ្ជីកាគណនេយ្យ ប្រព័ន្ធគ្រប់គ្រងកិច្ចប្រតិបត្តិការ និងការត្រួតពិនិត្យស្ថាប័នគ្រប់គ្រងដោយអនុលោមតាមស្តង់ដានៃការធ្វើសវនកម្មទូទៅនិងតាមស្តង់ដានៃការធ្វើសវនកម្មរបស់រដ្ឋាភិបាលដើម្បីផ្តល់ការធានាថា÷

**ក-** បណ្តាសកម្មភាពហិរញ្ញវត្ថុនិងសេដ្ឋកិច្ចត្រូវបានបង្ហាញយ៉ាងត្រឹមត្រូវតាមរយៈសេចក្តីថ្លែងការណ៍ និងតាមរបាយការណ៍

**ខ-** បណ្តាសកម្មភាពទាំងនេះត្រូវអនុវត្តដោយអនុលោមតាមគោលការណ៍គណនេយ្យទូទៅ

**គ-** ការត្រួតពិនិត្យនីតិវិធី និងការអនុវត្តដោយអនុលោមតាមច្បាប់បទបញ្ញាកិច្ចព្រមព្រៀង ប្រព័ន្ធគ្រប់គ្រង កិច្ចសន្យាកម្មវិធី និងលក្ខណៈវិនិច្ឆ័យផ្សេងទៀតដែលទាក់ទងដល់ចំណូលចំណាយ និងការប្រើប្រាស់ប្រភពធនធានរបស់រដ្ឋាភិបាល។

***អត្ថបទ÷*** *លោក* ***ឆាយ វណ្ណរិទ្ធ***

***ឯកសារយោង÷***

*១- ច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា*
*២- ច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម*
*៣- សៀវភៅណែនាំសវនកម្មផ្ទៃក្នុង*
៤-Ajao, O. S., Olamide, J. O., & Ayodeji, T. A. (2016). Evolution and Development of Audit. *Unique Research Journals*, p34.